រឿងរ៉ាវនៃភាពជាសះស្បើយ និងផ្សះផ្សា

*STORIES OF HEALING AND RECONCILIATION*

# VOICES

## OF FORMER KHMER ROUGE MEMBER-SURVIVORS



## សេចក្តីប្រកាស

*រឿងរ៉ាវនៃភាពជាសះស្បើយ និងផ្សះផ្សា៖ សម្លេងរបស់អតីតខ្មែរក្រហម* អាចចងក្រង និងបោះពុម្ពផ្សព្វផ្សាយទៅបានក្រោមជំនួយដ៏សប្បុរសរបស់ប្រជាជនអាមេរិក តាមរយៈទីភ្នាក់ងារអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ ហៅកាត់ថា USAID។ រាល់ខ្លឹមសារនៃសាច់រឿងទាំងនេះគឺជាការទទួលខុសត្រូវរបស់អង្គការធីភីអូ និងជាទស្សនៈរបស់អតីតខ្មែរក្រហមតែប៉ុណ្ណោះ ដែលខ្លឹមសារសាច់រឿងមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ USAID ឬក៏រដ្ឋាភិបាលរបស់អាមេរិកនោះឡើយ ។

## DISCLAIMER

Stories of Healing and Reconciliation: Voices of Former Khmer Rouge Member-Survivors was made possible through the generous support of the American People through the United States Agency for International Development (USAID). The contents herein are the sole responsibility of TPO Cambodia and are the opinions of the former Khmer Rouge member-survivors, and do not necessarily reflect the views of USAID or the United States Government.

រឿងរ៉ាវនៃភាពជាសះស្បើយ និងផ្សះផ្សា

*STORIES OF HEALING AND RECONCILIATION*

# VOICES

## OF FORMER KHMER ROUGE MEMBER-SURVIVORS

August 2016

# សេចក្តីឧទ្ទិស

សូមឧទ្ទិសសៀវភៅនេះទៅដល់អ្នកដែលបានបាត់បង់ជីវិតទាំងអស់ក្រោមរបបខ្មែរក្រហម និង អ្នករស់រានមានជីវិតដែលជាអតីតខ្មែរក្រហមដែលមានភាពក្លាហានទម្លាយភាពស្ងៀមស្ងាត់របស់ពួកគេ តាមរយៈការចែករំលែកប្រវត្តិនៃសោកនាដកម្មរបស់ពួកគេ ក៏ដូចជាការអភិវឌ្ឍន៍របស់ពួកគេឆ្ពោះទៅរកផ្លូវជាសះស្បើយ និងផ្សះផ្សា។

# Dedication

This book is dedicated to all those who perished under the Khmer Rouge regime—and to the former Khmer Rouge member-survivors who had the courage to break their silence in order to share their own traumatic histories as they progressed along their paths of healing and reconciliation.

# មាតិកា
# TABLE OF CONTENTS


02 បុព្វកថា
Foreword

04 អារម្ភកថា
Preface

06 សេចក្តីផ្តើម
Introduction

10 ផូ ធឿន
Phor Theun

14 ផូ ភុត
Phor Phut

18 ជឹម សារី
Chhim Sary

22 ហេង ហ៊ុម
Heng Houm

26 វុន ម៉េត
Vun Met

30 មូល ផាត
Mul Phat

34 រស់ ឡន
Ros Lorn

38 ខ្លូត ព្រីធា
Klot Pricha

42 ញែម ទន
Nhem Tuon

46 កង ជឹម
Korng Chem

# បុព្វកថា

អំពើព្រៃផ្សៃដែលបង្កឡើងដោយរបបកម្ពុជាប្រជាធិបតេយ្យ បានប៉ះពាល់ដល់សុខមាលភាពផ្លូវចិត្តរបស់ជនរងគ្រោះនៃរបបនេះយ៉ាងធ្ងន់ធ្ងរ។ ការជាសះស្បើយនៃរបួសផ្លូវចិត្ត និងការផ្សះផ្សាផ្លូវចិត្តក្នុងសង្គមកម្ពុជា វាទាមទារអោយមានការអន្តរាគមន៍ពហុវិស័យ ដែលក្នុងនោះមានការនិយាយពីរឿងរ៉ាវពិតរបស់អ្នករស់រានមានជីវិតដែលជាជនរង–គ្រោះ និងអ្នករស់រានមានជីវិតដែលជាអតីតខ្មែរក្រហម របស់របបកម្ពុជាប្រជាធិបតេយ្យ។

សៀវភៅនេះបានផ្តល់ឱកាសអោយអ្នករស់រានមានជីវិតដែលជាអតីតខ្មែរក្រហមរបស់របបកម្ពុជាប្រជាធិបតេយ្យ ដើម្បីនិយាយពីរឿងរ៉ាវរបស់ពួកគាត់ និងចែករំលែកនូវអារម្មណ៍ និងការសោកស្តាយរបស់ពួកគាត់។ រឿងរ៉ាវទាំងនេះគឺជារឿងរ៉ាវដែលគាត់បានលាក់ទុកក្នុងចិត្តគាត់ជិត៤០ឆ្នាំមកហើយ ដែលនេះគឺជាលើកទីមួយហើយគាត់មានឱកាសក្នុងការនិយាយរឿងរ៉ាវរបស់គាត់ប្រាប់យើងទាំងអស់គ្នា។

រឿងរ៉ាវរបស់អ្នករស់រានមានជីវិតដែលជាអតីតខ្មែរក្រហមរបស់របបកម្ពុជាប្រជាធិបតេយ្យ និងជនរងគ្រោះពីរបបនេះគឺមានសារសំខាន់ដូចគ្នា។ នៅពេលដែលគេទាំងពីរអាចបើកចិត្តរបស់ពួកគេក្នុងការស្តាប់ ក្នុងការស្វែងយល់ដោយសមានចិត្តល្អ និងទទួលស្គាល់វា នោះការផ្សះផ្សាផ្លូវចិត្តនឹងកើតមានឡើងនៅក្នុងសង្គមយើងមិនខាន។

អង្គការចិត្តសង្គមអន្តរវប្បធម៌កម្ពុជាកម្ពុជា សូមសរសើរដោយស្មោះចំពោះសេចក្តីក្លាហានរបស់អ្នករស់រានមានជីវិតដែលជាអតីតខ្មែរក្រហមទាំងនោះដែលបានចែករំលែករឿងរ៉ាវ និងអារម្មណ៍របស់ពួកគាត់។ យើងសង្ឃឹមថាការនិយាយរឿងរ៉ាវនេះវានឹងជួយពួកគាត់ ក៏ដូចជាអ្នករស់រានមានជីវិតដែលជាជនរងគ្រោះអោយឈានទៅរកការផ្សះផ្សា និងជាសះស្បើយផ្លូវចិត្ត។

បណ្ឌិត ឈឹម សុធារ៉ា

នាយកប្រតិបត្តិអង្គការធីភីអូកម្ពុជា

# FOREWORD

The atrocities committed by the Democratic Kampuchea (DK) regime continue to affect the mental health and psychological wellbeing of survivors of the regime. The healing of psychological scars and the reconciliation of Cambodian society needs a multi-disciplinary approach. One, of which, is storytelling from both victim-survivors and former DK member-survivors.

This book provides an opportunity for former DK member-survivors to tell their stories and express their feelings and remorse. These are the stories that they have been carrying with them for the past 40 years and this is the first time that they have had the opportunity to tell the world.

The stories of former DK member-survivors are as important as those of victim-survivors. Once they are both able to open their hearts and listen, to understand their stories with empathy and acceptance, then reconciliation can begin in our society.

Transcultural Psychosocial Organization truly admires these former KR member-survivors who had the courage to tell their stories and reveal their feelings. We hope that these stories will benefit both former DK member-survivors and victim-survivors alike in achieving reconciliation and healing.

Dr. Chhim Sotheara

TPO Executive Director

# អារម្ភកថា

ចាប់តាំងពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៦ អង្គការធីភីអូ កម្ពុជាបានអនុវត្តគម្រោងមួយដែលមានឈ្មោះថា "ការស្វែងរកពិត ការផ្សះផ្សា និងភាពជាសះស្បើយ" ដែលទទួលការឧបត្ថម្ភពីទីភ្នាក់ងារអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ ហៅកាត់ថា USAID។ គោលបំណងសំខាន់នៃគម្រោងនេះគឺដើម្បីលើកកម្ពស់ការផ្សះផ្សា និងភាពជាសះស្បើយតាមថ្នាក់មូលដ្ឋានក្នុងប្រទេសកម្ពុជា។ តាមរយៈគម្រោងនេះ យើងបានធ្វើការជាមួយទាំងអ្នករស់រានមានជីវិតដែលជាជនរងគ្រោះ និងអ្នករស់រានមានជីវិតដែលជាអតីតខ្មែរក្រហមដែលបានឆ្លងផុតពីសង្គ្រាមស៊ីវិល រាប់បញ្ចូលទាំងរបបហិង្សាបំផុតដែលកើតមានក្នុងប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា គឺរបបកម្ពុជាប្រជាធិបតេយ្យ ដែលភាគច្រើនស្គាល់ថាជារបបខ្មែរក្រហមបានគ្រប់គ្រងប្រទេស។

នៅពេលដែលយើងបានធ្វើការជាមួយនឹងអ្នករស់រានមានជីវិតដែលជាអតីតខ្មែរក្រហមនៅក្នុងគម្រោងបីឆ្នាំនេះ យើងយល់ថា ពួកគាត់មួយចំនួនក៏មានភាពឈឺចាប់ដោយសារតែការប៉ះទង្គិចផ្លូវចិត្តដែរ។ បន្ទាប់ពីការត្រិះរិះពិចារណាយ៉ាងយកចិត្តទុកដាក់ យើងជឿជាក់ថា ការហៅពួកគាត់ថាជាអ្នករស់រានមានជីវិតជាអតីតខ្មែរក្រហម គឺមានលក្ខណៈត្រឹមត្រូវជាង( ជាជាងគ្រាន់តែហៅពួកគាត់ថាជាសមាជិកខ្មែរក្រហម ) ពីព្រោះវាមិនត្រឹមតែអាចទទួលស្គាល់ការឈឺចាប់របស់ពួកគាត់តែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងឆ្លុះបញ្ចាំងពីតម្រូវការរបស់ពួកគាត់ទូលំទូលាយជាងមុននៅក្នុងដំណើការជាសះស្បើយ និងផ្សះផ្សា។

សៀវភៅនេះបង្ហាញអំពីរឿងរ៉ាវចំនួន១០របស់អ្នករស់រានមានជីវិតដែលជាអតីតខ្មែរក្រហមមកពីខេត្តចំនួន៤គឺ កំពង់ឆ្នាំង បាត់ដំបង ប៉ៃលិន និងបន្ទាយមានជ័យ។ រឿងរ៉ាវទាំងនេះ បានដកស្រង់ចេញពីសក្ខីកម្មរបស់ពួកគាត់ ពេលពួកគាត់ចូលរួមការព្យាបាលសក្ខីកម្មរបស់គម្រោង។ រឿងនៅក្នុងសៀវភៅនេះនឹងពិពណ៌នាត្រួសៗអំពីបទពិសោធន៍របស់ពួកគាត់នៅក្នុងសង្គ្រាមស៊ីវិល ក៏ដូចជាក្តីសង្ឃឹមរបស់ពួកគាត់សម្រាប់ប្រទេសជាតិនៅពេលអនាគត។

ការងារនេះពិតជាមិនអាចទៅរួចទេប្រសិនបើមិនមានអ្នកផ្តល់ប្រឹក្សារបស់អង្គការធីភីអូ ដែលបានផ្តល់ការព្យាបាលផ្លូវចិត្តសម្រាប់អ្នករស់រានមានជីវិតដែលជាអតីតខ្មែរក្រហមទាំងនេះ។ កញ្ញា Rhiana Holmes អតីតកម្មសិក្សាការីរបស់យើងមកពីសាកលវិទ្យាល័យ Denver គឺជាមនុស្សដ៏សំខាន់នៅក្នុងការងារនេះ ដោយបានជួយកែសម្រួលសាច់រឿងរបស់ពួកគេ ។

ចុងក្រោយ យើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះម្ចាស់ជំនួយ USAID សម្រាប់ការផ្តល់ជាថវិកាទៅលើការងារជាមួយនឹងអ្នករស់រានមានជីវិតដែលជាជនរងគ្រោះ និងអ្នករស់រានមានជីវិតដែលជាអតីតខ្មែរក្រហម អស់រយៈពេល៣ឆ្នាំ។ ជាចុងក្រោយ យើងក៏សូមថ្លែងអំណរគុណចំពោះអង្គការGIZ សម្រាប់ការគាំទ្រជាសម្ភារៈទៅលើគម្រោងនេះផងដែរ។

កញ្ញា អោម ចរិយា

# PREFACE

Between 2014 and 2016, a project called *Truth, Reconciliation, and Healing* was implemented by TPO Cambodia and funded by USAID. The primary goal of the project was to promote healing and reconciliation among survivors of the Khmer Rouge regime at the grassroots level. During this project we worked with both former Khmer Rouge victim-survivors and member-survivors who outlived the decades of civil war, including the most violent period in Cambodia's recent history—when the state of Democratic Kampuchea, better known as the "Khmer Rouge regime," ruled the country.

Over the course of the three-year project, we learned that a number of former Khmer Rouge members also suffered from significant psychological trauma. After thoughtful consideration, we believed that it was more appropriate to refer to them as former Khmer Rouge member-survivors rather than simply members, not only to acknowledge their suffering, but also to highlight the need for their broader inclusion in the healing and reconciliation process.

This book presents the stories of 10 former Khmer Rouge member-survivors from four provinces: Kampong Chhnang, Battambong, and two previous Khmer Rouge strongholds, Pailin and Banteay Meanchey provinces. Their stories are actual excerpts from the public testimonies they gave during their participation in Testimonial Therapy, the Project's main intervention for psychological trauma. Only brief descriptions of their experiences during the civil wars, as well as their hope for the future of the nation are included in this collection.

This work could not have been completed without the TPO counselors who provided psychotherapy and support to both the former Khmer Rouge victim-survivors and member-survivors. Ms. Rhiana Holmes, our former intern from the University of Denver, was pivotal in the creation of this work by selecting the initial excerpts and designing the format of the first draft.

Lastly, we extend our profound thanks to USAID for their financial support of our work with both former Khmer Rouge victim-survivors and member-survivors throughout the three-year project. We are also grateful for Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) for providing material support for the project as well.

—Om Chariya, M.A.

# សេចក្តីផ្តើម

មានមនុស្សក្រុមតូចប៉ុណ្ណោះដែលទទួលជ័យជំនះក្នុងសង្គ្រាមក្នុងចំណោមអ្នកដែលនៅរស់រានមានជីវិតពីសង្គ្រាមហែកហួរ។ ខណៈពេលអំពើប្រល័យពូជសាសន៍បានចារជាប្រវត្តិសាស្ត្រនៃប្រទេសជាច្រើន របបកម្ពុជាប្រជាធិបតេយ្យមានលក្ខណៈប្លែកពីគេ ដោយរបបនេះបានបំផ្លិចបំផ្លាញជាប្រព័ន្ធទៅលើប្រជាពលរដ្ឋនិងវប្បធម៌ប្រពៃណីរបស់ខ្លួន។ មហាអំណាចបរទេសមានការជាប់ទាក់ទងនឹងវិនាសកម្មនេះ។ ទោះបីរឿងរ៉ាវជាប្រវត្តិសាស្ត្រដ៏ច្បាស់លាស់នេះ ត្រូវបានបិទបាំងដោយឥទ្ធិពលនយោបាយនិងសង្គម ប៉ុន្តែឥទ្ធិពលនៃវិនាសកម្មនៅតែមើលឃើញយ៉ាងច្បាស់ក្រឡែតរហូតដល់បច្ចុប្បន្ននេះ។

ការពេញចិត្តចូលរួមក្នុងដំណើរការផ្សះផ្សា ពីសំណាក់បុគ្គលដែលបានបម្រើការងារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យគឺមានសារសំខាន់ជាខ្លាំង ដើម្បីសម្រេចបាននូវការផ្សះផ្សាដ៏ទូលំទូលាយ។ មិនមែនបុគ្គលទាំងអស់ដែលបានបម្រើការងារឲ្យរបបនេះសុទ្ធតែបានប្រព្រឹត្តអំពីសម្លាប់រង្គាលនោះទេ។ បុគ្គលខ្លះត្រូវបានទាក់ទាញឲ្យចូលរួមព្រោះតែមនសិការស្រឡាញ់ប្រទេសជាតិ ហើយបុគ្គលខ្លះទៀតត្រូវបានគេចាប់បង្ខំឲ្យបម្រើរបបនេះ។ ភាពខុសប្លែកគ្នាត្រូវបានស្តែងឲ្យឃើញតាមរយៈការប៉ះទង្គិចផ្លូវចិត្តនានា ដែលអ្នកនៅរស់រានមានជីវិតបានកើតមាន ហើយករណីគំរូដ៏តិចតួចប៉ុណ្ណោះដែលបានបង្ហាញជូននៅក្នុងការងារនេះ។

ការស្តារសង្គមកម្ពុជាដែលហែកច្រៀកយ៉ាងខ្ទេចខ្ទាំ តម្រូវឲ្យមានការធ្វើឲ្យជាសះស្បើយ និងការផ្សះផ្សាពីគ្រប់មជ្ឈដ្ឋាន។ ការបង្កើតបរិយាកាសមួយដែលប្រទេសជាតិទាំងមូលអាចប្រារព្ធទិវាកាន់ទុក្ខដើម្បីធ្វើឲ្យចងចាំនឹងផ្តល់ជាប្រយោជន៍ដ៏ធំធេងដែលគ្រប់ភាគីទាំងអស់អាចស្តែងចេញពីការបាត់បង់ និងទុក្ខសោករបស់ខ្លួន ការភ័យខ្លាចនិងវិប្បដិសារីរបស់ខ្លួន។ ខណៈពេលការយល់ឃើញនេះត្រឹមតែជាឧត្តមគតិ ការចងក្រងជាឯកសារទាំងនេះធ្វើឡើងក្នុងគោលបំណងចាប់ផ្តើមដំណើរការផ្តល់ជូនឡើងវិញនូវតម្លៃជាមនុស្សជាតិសម្រាប់គ្រប់ភាគីពាក់ព័ន្ធ ព្រមទាំងផ្តល់ឱកាសដល់អ្នកដែលនៅរស់រានមានជីវិតដែលរស់នៅស្ថិតក្នុងភាពឯកោ និងស្ងៀមស្ងាត់ ឲ្យនិយាយចេញនូវការឈឺចាប់របស់ខ្លួន។ ឆន្ទៈនៃការដឹកនាំរួមផ្សំជាមួយនឹងភាពខ្លាំងពីកំណើត ព្រមទាំងសមត្ថភាពក្នុងការធ្វើឲ្យមានភាពជាសះស្បើយរបស់ប្រជាជនកម្ពុជា អាចនាំឆ្ពោះទៅសម្រេចគោលបំណងនេះ ហើយនាំមកនូវសក្តានុពលសម្រាប់ការផ្សះផ្សាដ៏ធំធេង។

បណ្ឌិត Edward Palmer

# INTRODUCTION

There are few victors among those who survive the inhumanity of war. While genocide appears in the histories of many nations, Democratic Kampuchea was remarkable in the systematic destruction of their own people and culture. Foreign powers were also culpable. An exact historical account is obscured by social and political forces, but the effects of the devastation are still easily seen today.

In order to achieve greater reconciliation, an appreciation for the diverse conditions of those who served under the Democratic Kampuchea is essential. Not all who served committed atrocities. Some were driven by national pride and others were forced to serve. This diversity is evidenced by the psychological traumas endured by those who survived, and only a small sample is presented in this work.

Mending the torn social fabric of Cambodia requires healing and reconciliation on all levels. Creating an environment where the nation could mourn and memorialize collectively would be of great benefit—where all parties could express their loss and suffering, their fear and remorse. While this may seem idealistic, this modest collection of vignettes is intended to begin the process of humanizing all parties involved, as well as to give a voice to those suffering in isolation and silence.

The will of leadership combined with the inherent strength and resilience of the Cambodian people can further this goal and bring about the potential of greater reconciliation.

—Edward Palmer, Ph.D.

*ខ្ញុំមានការសោកស្តាយ ចំពោះរឿងរ៉ាវដែលកើតឡើង។ ក្នុងនាមជាបុគ្គលម្នាក់*
*ដែលធ្លាប់ចូលរួមចលនាខ្មែរក្រហម ខ្ញុំទទួលយក និងទទួលស្គាល់ថា*
*អ្នកខ្លះលះបង់ ដើម្បីប្រទេសជាតិ ខ្លះទៀតគ្មានជម្រើស និងត្រូវធ្វើ*
*តាមបញ្ជាគេ ហើយអ្នកខ្លះទៀត ប្រព្រឹត្តិអំពើឃោរឃៅជាច្រើន។*

វុន ម៉ែត

*I felt so much regret for the things that happened during that time. As a person who joined the KR movement, I accept and acknowledge that some scarified for the nation, some had no choice and were under orders, and others committed many atrocities.*

**VUN MET**



**ភួ ធឿន**
*អតីតមេក្រុមខ្មែរក្រហម*

**Phor Theun**
*Former KR Team Leader*

ពេលដែលគេបង្ខំខ្ញុំឲ្យធ្វើជាមេក្រុម ខ្ញុំសង្ឃឹម
ថាធ្វើវាឲ្យត្រូវ ប៉ុន្តែតាមការពិត
វាបែរជាខុសទៅវិញ ។

*When I was forced to take the position of team leader, I had the hopes of doing it right, but in reality—it went all wrong.*

នៅឆ្នាំ១៩៧៥ គេឲ្យខ្ញុំ ធ្វើជាមេកងតូចមើលការខុសត្រូវ៣០គ្រួសារ។ ដោយតាមបញ្ជារបស់ថ្នាក់ដឹកនាំ អង្គការបានរៀបចំគូស្រករជាមួយនឹងយោធាម្នាក់ដែលស្នើរៀបការជាមួយនឹងខ្ញុំ។ មុនពេលដែលពួកយើងជួបមុខគ្នានៅក្នុងពិធីរៀបជាច្រើនគូរ ខ្ញុំមិនដឹងថាគាត់ជានរណា ហើយនរណាដែលនឹងត្រូវមករៀបការជាមួយខ្ញុំនោះទេ។

បន្ទាប់ពីរបបនេះដួលរលំ ខ្ញុំក៏បានមករស់ស្រុកកំណើតវិញ ក្រោមការរៀបចំរបស់រដ្ឋាភិបាល។ ថ្ងៃមួយមេឃុំបានប្រាប់ខ្ញុំថា មានទាហានម្នាក់គេមកសួររកឈ្មោះខ្ញុំ និងចោទថាខ្ញុំថាបានសម្លាប់និងលួចយកមាសបងស្រីរបស់គាត់ និងថាចង់មកសងសឹកមកលើខ្ញុំទៀតផង។ រឿងនេះធ្វើឲ្យខ្ញុំខ្លាចជាខ្លាំង រួចខ្ញុំចាប់ផ្តើមសួរខ្លួនឯងម្តងហើយម្តងទៀត ថាមានធ្លាប់ធ្វើអ្វីខុសឬទេ? ខ្ញុំមិនដែលសម្លាប់មនុស្សណាម្នាក់ទេ សូម្បីតែគិតក៏មិនដែលបានគិតផង។ តែយ៉ាងណា ខ្ញុំគិតថាខ្ញុំក៏ខុសដែរ ខុសដោយមិនបានជួយអ្នកដែលនៅក្រោមការគ្រប់គ្រងរបស់ខ្ញុំ ដោយសារខ្ញុំមិនដែលបានដឹងមុន មិនបានឃើញគេចាប់ចងអ្នកណាម្នាក់ផ្ទាល់នឹងភ្នែកខ្ញុំផង។ ខ្ញុំពិតជាមិនអាចជួយអ្វីដល់ពួកគេបានមែន។

ខ្ញុំក៏វេទនាដូចអ្នកដទៃទៀតដែរ ហើយខ្ញុំមានអារម្មណ៍ថាខុសចំពោះការបានចូលរួមក្នុងចលនាខ្មែរក្រហម។ ខ្ញុំមិនបានដឹងទេថាខ្ញុំបានប្រព្រឹត្តកំហុសណាមួយរឺអត់។ បន្ទាប់ពីបានចែករំលែករឿងរ៉ាវដល់អង្គការធីភីអូ ខ្ញុំមានការយល់ដឹងជាងមុនច្រើន និងធូរជាងមុនច្រើន។





In 1975, I was forced to become the team leader of a small unit that controlled 30 families. By order of the KR leadership, I married a soldier who had previously courted me. Prior to seeing him again at the mass marriage, I didn't know who I was going to marry.

After the KR fell, I returned home under the orders of the new government. One day, the commune chief told me that a soldier came by and accused me of killing her sister and stealing her gold, and that he was seeking revenge on me. This frightened me. I kept asking myself if I had done anything wrong. I never killed anyone and I never thought about killing. I felt responsible because I didn't help the people I supervised, but I never knew what would happen in advance nor had I ever seen anyone get arrested. I couldn't do anything to help them.

I was in misery like everyone else and felt guilty for being part of the KR regime. I didn't know whether or not I had committed any wrongdoings. After telling my story to TPO, I gained understanding and I felt relief.





ខ្ញុំតែងតែទៅវត្ត និងធ្វើបុណ្យធ្វើទានដើម្បីជម្រះរាល់
កំហុសឆ្គងរបស់ខ្ញុំ។ ខ្ញុំបានទៅវត្ត និងធ្វើបុណ្យជាមួយ
នឹងជនរងគ្រោះ និងរាប់អានជាមួយនឹងពួកគេ។

*I keep going to pagodas and joining Buddhist ceremonies to purify all my wrongdoings. I have joined the Buddhist ceremonies with victim-survivors and make friends with them.*



ផូ ភុត
អតីតពេទ្យខ្មែរក្រហម

**Phor Phut**
*Former KR Medic*

ខ្ញុំមិនដែលមានឱកាសនិយាយចេញពីរឿងរ៉ាវ
របស់ខ្ញុំនោះទេ។ ដូច្នេះ នៅពេលដែលខ្ញុំរំលឹក
ឡើងវិញពីរបបខ្មែរក្រហម ខ្ញុំចាប់ផ្តើមយំ។

*I never had the chance to tell my story.
So, when I was reminded of the KR regime,
I began to weep.*

នៅក្នុងឆ្នាំ១៩៧៣និងឆ្នាំ១៩៧៤ ខ្ញុំត្រូវគេបំបែកចេញពីគ្រួសារ និងបង្រៀនឲ្យធ្វើជាពេទ្យខ្មែរក្រហមម្នាក់។ ក្នុងនាមជាពេទ្យសម័យនោះ ខ្ញុំតែងបានឃើញពួកទាហានខ្មែរក្រហមសំលាប់មនុស្សនៅនឹងមុខ។ ពេលខ្លះ ខ្ញុំក៏ប៊ិះនឹងត្រូវបានគេយកទៅសម្លាប់នៅក្រោមបញ្ជារបស់ពួកគេនោះដែរ។

ខ្ញុំមានការសោកស្តាយចំពោះការដែលបានចូលរួមចំណែកជាផ្នែកនៃរបបដែលគួរឲ្យស្អប់ខ្ពើមមួយនេះ ប៉ុន្តែខ្ញុំមិនបានស្ម័គ្រចិត្តទេ គឺខ្ញុំត្រូវបានបង្ខំ ដែលបានធ្វើឲ្យខ្ញុំត្រូវរស់នៅក្នុងស្ថានភាពភ័យខ្លាច និងរងទុក្ខអស់រយៈពេលជាងសាមសិបឆ្នាំ។ ខ្ញុំមានការហត់នឿយយ៉ាងខ្លាំង។

ខ្ញុំមានអារម្មណ៍ថាគ្មាននរណាម្នាក់ដែលខ្ញុំអាចចែករំលែកពីកង្វល់នានាដែលខ្ញុំមាន លើកលែងតែអង្គការធីភីអូ។ នៅពេលមួយដែលខ្ញុំព្យាយាមនិយាយជាមួយកូនៗរបស់ខ្ញុំ ពួកគេមិនបានជឿខ្ញុំ និងយល់ពីស្ថានភាពខ្ញុំនោះទេ។ នៅពេលដែលចាប់ផ្តើមរំលឹកឡើងវិញពីការចងចាំទាំងឡាយនៃរឿងអតីតកាលក្នុងកំឡុងពេលនៃការព្យាបាលរបស់អង្គការធីភីអូ ខ្លួនរបស់ខ្ញុំចាប់ផ្តើមញ័រ ប៉ុន្តែនៅពេលដែលខ្ញុំនិយាយជាមួយអ្នកប្រឹក្សា–យោបល់ គាត់បានស្តាប់ខ្ញុំនិងគាំទ្រផ្លូវចិត្តរបស់ខ្ញុំ។ ការធ្វើបែបនេះ វាបានធ្វើឲ្យខ្ញុំមានអារម្មណ៍ធូរស្រាលជាច្រើន។ មួយខែបន្ទាប់ពីបានទទួលនូវការព្យាបាល អារម្មណ៍ធូរស្រាលនៅតែបន្តប្រសើរជាងមុន។ ខ្ញុំមានអារម្មណ៍ថាទទួលបាននូវកំលាំងកាយនិងចិត្តច្រើនដែលវាអាចធ្វើឲ្យខ្ញុំមានការគិតប្រសើរជាងមុន។ ខ្ញុំបានចាប់ផ្តើមចូលរួមក្នុងសកម្មភាពសង្គមជាច្រើនផ្សេងទៀតនិងញឹកញាប់ជាងមុន។ ការព្យាបាលវាពិតជាល្អណាស់សម្រាប់ខ្ញុំ ហើយខ្ញុំសង្ឃឹមថាអ្នកផ្សេងទៀតអាចនឹងទទួលបាននូវការព្យាបាលនេះដូចខ្ញុំដែរ។





Between 1973 and 1974, I was separated from my family and taken to be trained as a medic. As a medic, I witnessed KR soldiers killing people. I was also about to be killed under orders of the regime. I regret that I was part of such an abhorrent regime, but I didn't volunteer. I was forced, which caused me to live in fear and suffering for over 30 years. I was exhausted.

I felt that there was no one I could share my worries with except TPO. When I tried to talk with my children, they didn't believe me or understand me. When recalling memories from my past during therapy, my body began to shake. But when I talked with my counselor, he listened to me and he supported me. This allowed me to release all of my feelings.





ខ្ញុំមានមានកម្លាំងច្រើនជាងមុន ដែលអាចធ្វើឲ្យ
ខ្ញុំមានការគិតបានច្បាស់ជាងមុន។ ខ្ញុំចាប់ផ្តើម
ចូលរួមសកម្មភាពនៅខាងក្រៅបានច្រើន
ជាងមុន។ ការព្យាបាលនេះគឺល្អណាស់
សម្រាប់ខ្ញុំ ហើយខ្ញុំសង្ឃឹមថា អ្នកដទៃក៏
អាចទទួលសេវាទាំងនេះបានដែរ។

*I feel more energy in my mind and body, which allows me to think clearly. I'm also beginning to attend more social events. My treatment was very good for me, and I hope that others can also receive these services.*



ឈឹម សារី **Chhim Sary**

អតីតពេទ្យខ្មែរក្រហម *Former KR Medic*

ខ្ញុំចង់បានកិត្តិយសសម្រាប់ការលះបង់របស់ខ្ញុំ
សម្រាប់ប្រទេសជាតិក្នុងពេលសង្គ្រាម។
ប៉ុន្តែចុងក្រោយ គេបានហៅខ្ញុំថាជា
អ្នកបំផ្លាញជាតិទៅវិញ។

*I wanted to be honored for my sacrifices during the wars, which I did for the sake of the nation. But eventually, I was called a traitor to the nation.*

ខ្ញុំបានចូលរួមធ្វើសង្គ្រាមព្រោះខ្ញុំចង់ជួយជាតិរបស់ខ្ញុំ។ គេឲ្យខ្ញុំទៅរៀនពេទ្យដើម្បីព្យាបាលអ្នកជំងឺនៅសមរភូមិ។ ក្នុងឆ្នាំ១៩៧៨អង្គការឲ្យខ្ញុំចាប់ដៃជាមួយនឹងប្រធានសហករណ៍ម្នាក់។ ក្នុងឆ្នាំ១៩៧៩ពេលខ្ញុំមកដល់ភូមិរបស់ប្ដីខ្ញុំ ប្រជាជនមួយចំនួនគិតថា ខ្ញុំព្យាបាលអ្នកជំងឺក្នុងសមរភូមិដោយមិនបានរៀនសូត្រត្រឹមត្រូវ។

អ្នកភូមិបាននិយាយថា ពេទ្យសម័យអាពត មិនបានទៅរៀនសូត្រឯណាចេះដឹងពិតប្រាដកទេ។ ខ្ញុំមានអារម្មណ៍តូចចិត្ត ដែលត្រូវគេរើសអើង។ ខ្ញុំគិតថាយើងចង់ជួយគេសោះ បែរជាគេនិយាយបែបហ្នឹងទៅវិញ។

ទោះបីជា ខ្ញុំជាពេទ្យសម័យអាពត ខ្ញុំក៏ចង់ទទួលខុសត្រូវខ្លះដែរ ចំពោះអ្នករងនូវទារុណកម្ម ក្នុងរបបដែលបានបង្រៀនខ្ញុំឲ្យជួយជីវិតអ្នកដទៃ។ នាងខ្ញុំសូមអរគុណចំពោះមិត្តភក្តិខ្ញុំនិងអតីតអតិថិជនធីភីអូ បានលើកទឹកចិត្តខ្ញុំឲ្យរៀបរាប់ពីជីវិត ហើយវាជួយឲ្យខ្ញុំធូរស្បើយពីការឈឺចាប់ដែលកប់នៅក្នុងជម្រៅបេះដូងជាង៣០ឆ្នាំកន្លងមកនេះ។





I joined the military because I wanted to help my country. I was given medical training in order to treat soldiers wounded in battle. In 1978, I was forced to marry a cooperative chief. When I arrived at my husband's village, many there felt that I had been not properly trained.

They would say that medics trained during the Pol Pot regime had not studied at all. I felt completely demoralized and ostracized by everyone in the village. I felt that all of my efforts to save people were done in vain due to the harsh words of the village people.

Even though I was a medic, I took collective responsibility for the people who had been tortured under the same regime that trained me to help others. Thanks to a former client of TPO and a friend of mine, I was encouraged to share my story and be relieved of the pain I was holding onto for 30 years.





ខ្ញុំសង្ឃឹមថាក្មេងជំនាន់ក្រោយ និង
សាធារណៈជនរៀនសូត្រពីប្រវត្តិសាស្ត្រ
របស់យើងដើម្បីជៀសវាងមានការរើសអើង
ទៅលើអ្នកដែលស្ម័គ្រចិត្តចូលរួមជាមួយនឹង
របបប៉ុលពតនៅក្នុងគោលបំណងល្អ។ សូមឲ្យ
ពួកយើងទាំងអស់ចេះរួបរួមគ្នា ដើម្បីជៀសវាង
កុំឲ្យមានរបបនេះជាលើកទីពីរទៀត។ សូមឲ្យ
ប្រទេសជាតិរស់នៅប្រកបដោយសន្តិភាព។

*I hope the next generation and public will learn our history in order to prevent the discrimination of those who volunteered for the Pol Pot regime in good faith. May all of us unite in order to prevent a second regime. May this nation live in peace.*

# ហេង ហ៊ុម Heng Houm

*Former KR Cooperative Leader*

អតីតប្រធានសហករណ៍ខ្មែរក្រហម



ខ្ញុំមានអារម្មណ៍ថា ធ្វើខុសដែលមិនអាចការពារ
អ្នកដែលនៅពីក្រោមការគ្រប់គ្រងរបស់ខ្ញុំ។
សូម្បីតែពូរបស់ខ្ញុំ ក៏ត្រូវគេសម្លាប់
យ៉ាងព្រៃផ្សៃដែរ។

*I felt guilty for not being able to protect those who were under my supervision. Even my uncle was brutally killed.*

ឆ្នាំ១៩៧០ អ្នកភូមិខ្ញុំចាប់ផ្ដើមមានការពិបាកក្នុងការរស់នៅ។ ពួកលន់នល់ជឿថាពួកខ្ញុំចូលដៃជាមួយពួកខ្មែរក្រហម ឯពួកខ្មែរក្រហមថាពួកខ្ញុំចូលដៃជាមួយពួកលន់នល់។ ឆ្នាំ១៩៧៣ ពួកខ្មែរក្រហមបានចាប់ខ្លួនមេភូមិរបស់ពួកយើង។ ភ្លាមៗបន្ទាប់ពីនោះ អង្គការចាត់តាំងឲ្យខ្ញុំត្រូវទៅក្តាប់សហករណ៍។ ឆ្នាំ១៩៧៦ នៅខែមីនា ប្រជាជនសហករណ៍ខ្ញុំត្រូវជម្លៀស ហើយខ្ញុំក៏មានអារម្មណ៍ធូរស្រាលដោយគិតថាអស់តួនាទីទៀតហើយ។

ខ្ញុំតែងមានអារម្មណ៍ថាខុសយ៉ាងធ្ងន់ តែទោះយ៉ាងណា ខ្ញុំមិនត្រូវបានគេប្រាប់ឲ្យដឹងមុនពីការចាប់ខ្លួនដែលនឹងកើតឡើង  ហើយខ្ញុំក៏រឹតតែមិនអាចធ្វើអ្វីបានទៀតដើម្បីបញ្ឈប់ពួកគេដែរ។ ខ្ញុំរឹតតែមិនអាចជួយការពារពូរបស់ខ្ញុំម្នាក់នៅពេលដែលទាហានខ្មែរក្រហមបានចាប់រូបគាត់។ ខ្ញុំពិតជាមិនអាចធ្វើអ្វីបានទាល់តែសោះ។ នៅពេលដែលចាប់ផ្ដើមមានសាលាក្ដីសម្រាប់កាត់ក្ដីមេដឹកនាំខ្មែរក្រហម ខ្ញុំមានការភ័យខ្លាចថាគេអាចនឹងចាប់ខ្លួនខ្ញុំដោយសារតែការចូលរួមជាមួយរបបមួយនេះ។

ទើបតែខែកក្កដា ឆ្នាំ២០១៥ ថ្ងៃដែលមន្ត្រីរបស់អង្គការធីភីអូ មកជួបមកសាកសួរនិងផ្ដល់ឱកាសឲ្យខ្ញុំ បាននិយាយចេញនូវរឿងពិតក្នុងចិត្តដែលខ្ញុំបានលាក់ទុកអស់រយៈពេលជាង៣០ឆ្នាំកន្លងមក។ ក្នុងពេលនោះ ខ្ញុំបានបញ្ចេញនូវការសោកស្ដាយនិងការឈឺចាប់របស់ខ្ញុំចេញមក។ បន្ថែមពីលើនេះទៀត ខ្ញុំបានដឹងថា ខ្ញុំនឹងមិនត្រូវបានគេចោទប្រកាន់និងកាត់ក្ដីសម្រាប់ការចូលរួមនេះទេ  ហើយនេះវាពិតជាបានធ្វើ  ឲ្យខ្ញុំធូរស្រាលយ៉ាងខ្លាំងអស់រយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ។ ខ្ញុំលែងមានអារម្មណ៍ដក់ជាប់ និងជាប់ជំពាក់ជាមួយនឹងរឿងអតីតកាលទៀតហើយ។





In 1970, my village became very difficult to live in. The Lun Nol regime believed we were colluding with the KR, while the KR thought we were colluding with Lun Nol. In 1973, our village chief was arrested. Shortly afterwards, I was ordered to control a group of cooperatives. In March of 1976, the people in my cooperatives were evacuated and I was relieved of my duties.

I was full of guilt, however, because I was never told of the arrests in advance, nor could I do anything to stop them. I couldn't even protect my uncle when they arrested him. I was completely powerless. When the tribunal for the KR leaders began, I feared that I would be arrested for my participation in the regime.

In July of 2015, TPO gave me the opportunity to share the pain I had held inside for over 30 years. On that day, I let go of my feelings of regret and pain. Additionally, I was informed that I would not be tried for my participation in the regime. This brought me much needed relief after many years. I no longer feel attached to the past.





ខ្ញុំចង់ឱ្យគេដឹងពីវិប្បដិសារីរបស់ខ្ញុំសម្រាប់ការឈឺចាប់និង
សោកនាដកម្មក្នុងអំឡុងពេល៣ឆ្នាំ ៨ខែ ២០ថ្ងៃនៃរបបប៉ុលពត។

*I want to let the people know of my remorse for the pain*
*and tragedy caused during the three years eight months*
*and 20 days of the Pol Pot regime.*

## វ៉ុន ម៉េត Vun Met

*អតីតប្រធានកងអនុសេនាធំខ្មែរក្រហម Former KR Company Leader*



ខ្ញុំមានអារម្មណ៍សោកស្តាយយ៉ាងខ្លាំងចំពោះរឿងរ៉ាវ
ដែលបានកើតឡើងក្នុងពេលនោះ។ ក្នុងនាមជា
បុគ្គលម្នាក់ដែលធ្លាប់ចូលរួមចលនាខ្មែរក្រហម
ខ្ញុំទទួលយក និងទទួលស្គាល់ថា អ្នកខ្លះលះបង់
ដើម្បីប្រទេសជាតិ ខ្លះទៀតគ្មានជម្រើស
និងត្រូវធ្វើតាមបញ្ជាគេ ហើយអ្នកខ្លះទៀត
ប្រព្រឹត្តិអំពើឃោរឃៅជាច្រើន ។

*I felt so much regret for the things that happened during that time. As a person who joined the KR movement, I accept and acknowledge that some scarified for the nation, some had no choice and were under orders, and others committed many atrocities.*

ក្នុងឆ្នាំ១ ៩ ៧ ១ ទាហានខ្មែរក្រហមបានសម្លាប់ពូរបស់ខ្ញុំ។ ហេតុការណ៍នេះធ្វើឲ្យខ្ញុំតក់ស្លុតយ៉ាងខ្លាំង។ ឆ្នាំបន្ទាប់ទៀត ខ្ញុំបានសម្រេចចិត្តចូលរួមជាមួយនឹងខ្មែរក្រហម ដើម្បីស្វែងរកពីមូលហេតុដែលពូរបស់ខ្ញុំត្រូវបានសម្លាប់។ ក្នុងឆ្នាំ១៩៧៥ គេបានឲ្យខ្ញុំដឹកនាំទាហាន១០០នាក់។ ខ្ញុំគិតថាពេលខ្ញុំកាន់តួនាទីនេះ វាជាទំនួលខុសត្រូវរបស់ខ្ញុំ ក្នុងការអប់រំទាហានឲ្យបម្រើប្រទេសជាតិ និងការពារទឹកដីពីប្រទេសវៀតណាម។

ក្នុងឆ្នាំ១៩៨៤ ខ្ញុំបានដើរជាន់មីន ដាច់ជើងត្រឹមកជើង។ បន្ទាប់ពីគ្រោះថ្នាក់នេះ ខ្ញុំចាប់ផ្តើមគិតច្រើន។ ខ្ញុំមានអារម្មណ៍ធ្លាក់ទឹកចិត្ត ហើយតែងតែគិតពីរបបខ្មែរក្រហមជាប់ជានិច្ច។ ខ្ញុំចូលរួមទទួលខុសត្រូវទៅលើទង្វើរបស់មេដឹកនាំខ្មែរក្រហម ថ្វីបើខ្ញុំមិនដែលធ្វើអាក្រក់ចំពោះប្រជាជនខ្មែរក៏ដោយ។ ទោះបីជាខ្ញុំមានចេតនាល្អ ពេលចូលរួមចលនានេះ ប៉ុន្តែឥលូវយល់ឃើញថា មិនមែនមនុស្សទាំងអស់ដែលចូលរួមចលនានោះ មានចេតនាល្អទាំងអស់នោះទេ ។

នេះជាលើកទីមួយហើយ ដែលខ្ញុំមានភាពក្លាហាននិយាយពីការឈឺចាប់ពីជីវិតលំបាក និងទុក្ខព្រួយរបស់ខ្ញុំ។ វាជាការពិត ដែលការព្យាបាលនេះជួយឲ្យមានភាពធូរស្បើយ។ វាធ្វើឲ្យខ្ញុំសំរាន្តលក់បានច្រើនជាងមុន។



In 1971, my uncle was killed by a KR soldier. This shocked me very deeply. The following year, I decided to join the KR in order to find out how and why my uncle was killed. In 1975, I was promoted to lead 100 soldiers. I felt that in this position of power, it was my responsibility to educate soldiers on how to adequately protect and serve Cambodia by protecting the country from the Vietnamese.

In 1984, I stepped on a land mine which caused me to lose my foot from the ankle down. After this accident, I started thinking too much. I fell into a depression and constantly thought about the KR regime. I began to take collective responsibility for the actions of the KR leadership, despite never causing harm to Khmer people myself. Although I joined with good intentions, I now see that not everyone else did the same.

This is the first time that I dared to speak about the pain from my difficult and sad life. It is true that this treatment helps provide relief. It has allowed me to sleep better.





*ខ្ញុំសង្ឃឹមថាថ្ងៃណាមួយអ្នករស់រានមានជីវិតដែលជា*
*ជនរងគ្រោះទាំងឡាយនឹងឈប់មានការរើសអើង*
*និងគិតថាខ្មែរក្រហមទាំងអស់សុទ្ធតែជាមនុស្សអាក្រក់។*

*I hope that victim-survivors will one day cease their discrimination and know that not all former Khmer Rouge members are bad people.*



**មូល ផាត**
*អតីតទាហានខ្មែរក្រហម*

**Mul Phat**
*Former KR Soldier*

នៅពេលដែលខ្ញុំឃើញការសម្លាប់ វាហាក់ដូចជា
ខ្ញុំកំពុងមើលរឿងកុន។ រូបភាពនៃការសម្លាប់
នោះបានដក់ជាប់នៅក្នុងខួរក្បាលរបស់ខ្ញុំ
ដែលធ្វើឲ្យខ្ញុំពិបាកគេងយ៉ាងខ្លាំង។

*When I witnessed the killings, it was as if I was watching a film. The images of the killings kept replaying in my mind and made it very difficult for me to sleep.*

ឆ្នាំ១៩៧៥ ទាហានខ្មែរក្រហម បានជម្លៀស និងបំបែកខ្ញុំអោយរស់នៅបែកពីម្តាយ។ ក្នុងឆ្នាំ១៩៧៦ គេបានឲ្យខ្ញុំចូលរួមមិទិញមើលផ្ទាល់នូវការវាយសម្លាប់អ្នកទោសជាច្រើន ដែលមានទោសផ្សេងៗគ្នា។

ឆ្នាំ១៩៧៨ ព្រោះតែការពារជីវិត ខ្ញុំក៏សម្រេចចិត្តចូលរួមជាទ័ពខ្មែរក្រហម។ នៅឆ្នាំ១៩៨០ ខ្ញុំក៏បានប្រយុទ្ធជាមួយកងទ័ពវៀតណាម។ ខ្ញុំបាញ់ទៅពួកគេ ទោះបីជាពួកគេជាសត្រូវឬអត់។ ខ្ញុំមិនមានគំនិតនឹងចេតនាក្នុងការសម្លាប់អ្នកណានោះទេ ប៉ុន្តែវាមិនអាចគេចបានព្រោះនេះជាបញ្ជាថ្នាក់លើ។ ខ្ញុំខ្លាចចំពោះការបាត់បង់អាយុជីវិតខ្ញុំហើយជម្រើសចុងក្រោយមានតែការពារខ្លួន។

ខ្ញុំកម្របាននិយាយវាចេញណាស់ ព្រោះប្រជាជននៅតំបន់ខ្ញុំមិនឲ្យរំលឹក ម្យ៉ាងពេលរំលឹក វាហាក់ដូចថ្មីសម្រាប់ខ្ញុំ ដូច្នេះហេតុការណ៍ទាំងនេះនៅតែដក់ជាប់ក្នុងចិត្តរបស់ខ្ញុំជានិច្ច រហូតដល់ខ្ញុំបានគេងយល់សប្តិអាក្រក់ស្ទើររាល់យប់។

ខ្ញុំបានចូលរួមព្យាបាលផ្លូវចិត្តជាមួយនឹងអង្គការធីភីអូ ខ្ញុំអាចទម្លាយរឿងរ៉ាវដែលបានលាក់ទុកក្នុងចិត្ត និងចងក្រងរឿងរ៉ាវរបស់ខ្ញុំសម្រាប់កូនចៅជំនាន់ក្រោយ និងប្រជាជនទូទៅបានដឹង និងយល់ពីជីវិតដ៏សែនឈឺចាប់របស់ខ្ញុំ ។



In 1975, KR soldiers evacuated and separated me from my mother. In 1976, I was summoned many times to witness the killings of many people for various offenses.

In 1978, in order to protect my own life, I decided to become a KR soldier. In 1980, I went to fight the Vietnamese army. I fired at them whether or not they were enemies. I didn't intend to kill others, but I couldn't avoid this because these were my orders. I was afriad of losing my own life and felt that my only choice was to protect myself. I hardly spoke about my story because the people in my region didn't want to talk about what had happened. Whenever I recalled it, however, it seemed like it was just happening to me. These events occupied my mind to the point of having nightmares every night.

When I participated in therapy, I disclosed all the stories I had tried to keep hidden in my mind. I also documented my story for the next generation, as well as the for the people of Cambodia, so that they could learn about my painful life.





នៅពេលដែលខ្ញុំរំលឹករឿងរបស់ខ្ញុំ ខ្ញុំមានអារម្មណ៍
ឈឺចាប់តិចជាងមុន។ ខ្ញុំចិញ្ចឹមមាន់ទា សម្រាប់
ចិញ្ចឹមជីវិតសព្វថ្ងៃ។ នៅពេលដែលខ្ញុំធ្វើការ ខ្ញុំកម្រ
គិតអំពីរឿងដែលធ្វើឲ្យខ្ញុំមិនសប្បាយចិត្ត។ ខ្ញុំមាន
អារម្មណ៍ធូរស្បើយ។ ឥលូវខ្ញុំគេងលក់ជាងមុន
និងឈប់យល់សប្តិអាក្រក់ទៀត។

*When I remember my story now, I feel less pain. I raise ducks and chickens for a living today. While working, I rarely think about the things that make me unhappy. I feel relieved. I now sleep better and I no longer have nightmares.*



## រស់ ឡន Ros Lorn

អតីតកម្មកររោងចក្រខ្មែរក្រហម

*Former KR Factory Worker*

អ្វីដែលធ្វើឲ្យខ្ញុំឈឺចាប់បំផុត អស់រយៈពេល
ជាង៣០ឆ្នាំគឺការព្យាយាមរកចម្លើយ
"តើខ្ញុំជាអ្នកណា?"

*What caused me the most pain for 30 years was my attempt to answer the question, "Who am I?"*

ខ្មែរក្រហមបំបែកខ្ញុំចេញពីឪពុកម្តាយនៅពេលអាយុ១៣ឆ្នាំឲ្យទៅនៅកងកុមារ។ បន្ទាប់មកគេបានឲ្យខ្ញុំទៅធ្វើការរោងចក្រក្រឡឹងនៅភ្នំពេញរហូតដល់ឆ្នាំ១៩៧៩។ ពេលកងទ័ពវៀតណាមចូលមកជិតដល់ភ្នំពេញ ខ្មែរក្រហមបានឲ្យកម្មករទាំងអស់ ទៅច្បាំងជាមួយទ័ពវៀតណាម ទាំងដែលអ្នកខ្លះគ្នាមិនដែលធ្លាប់កាន់កាំភ្លើងសោះ។

ថ្ងៃមួយ ពួកវៀតណាមបាញ់ខ្ញុំបាក់ភ្លៅឆ្វេង ដើរមិនរួច។ វាចាប់ខ្ញុំយកទៅវាយសួរចម្លើយ វាយដំខ្ញុំយ៉ាងខ្លាំង ហើយក៏បញ្ជូនខ្ញុំទៅដាក់គុកងងឹតរយៈពេលបីខែ។ បន្ទាប់មកទៀត គេក៏បានបញ្ជូនឲ្យខ្ញុំទៅនៅគុកធំបីឆ្នាំបន្តទៀត។

ពេលដែលគេដោះលែងខ្ញុំចេញពីគុក ខ្ញុំបានត្រលប់ទៅផ្ទះវិញ។ មេភូមិ និងមិត្តភក្តិរបស់ខ្ញុំបានគិតថាខ្ញុំជាឈ្លបរបស់រដ្ឋាភិបាលដែលវៀតណាមបានចូលរួមបង្កើតរដ្ឋាភិបាលនេះឡើង។ ពួកគេបានគិតថា ខ្ញុំបានសម្លាប់ប្រជាជនខ្មែរ ដែលពាក្យទាំងនេះធ្វើឲ្យអារម្មណ៍ខ្ញុំវិលវល់រហូតមក។ វាសំខាន់ណាស់ដែលយើងត្រូវទទួលស្គាល់ថាព័ត៌មានត្រូវបានលាក់ជិតពីកម្មករ និងទាហានខ្មែរក្រហមជាច្រើននាក់ ហើយពួកគេក៏មិនបានដឹងពីការសម្លាប់យ៉ាងរង្គាល និងអំពើទារុណកម្មក្រោមការដឹកនាំរបស់មេដឹកនាំខ្មែរក្រហមនោះដែរ។

ខែមករា ឆ្នាំ២០១៦ មន្ត្រីអង្គការ ធីភីអូបានមកសាកសួរ និងផ្តល់ឱកាសឲ្យខ្ញុំរៀបរាប់ពីព្រឹត្តិការណ៍ទាំងអស់ និងយកចិត្តទុកដាក់ស្តាប់រឿងខ្ញុំ ធ្វើឲ្យខ្ញុំមានអារម្មណ៍ធូរស្រាល ស្រឡះក្នុងចិត្តច្រើនជាងមុនពេលដែលខ្ញុំលាក់រឿងទុកក្នុងចិត្ត។



When I was 13 years old, the KR separated me from my parents and sent me to live in a Child Unit. I was assigned to work in a tile factory until 1979. When the Vietnamese troops had nearly reached Phnom Penh, the KR ordered all workers to fight, despite not having any military training.

One day, a Vietnamese soldier shot me in my upper left leg and I couldn't walk. They arrested me and I was tortured during my initial interrogations. Later, they sent me to a dark prison for three months. After that, I was sent to a large prison for three years.

When I was finally released from prison and returned home, my village chief and friends thought that I was a spy of the government that the Vietnamese had installed during their occupation. They thought that I had killed Khmer people and I was profoundly confused by this. It is important to recognize that information was concealed from many KR workers and soldiers, and that they had no knowledge of the mass killings and torture ordered by the KR leadership.

In January of 2016, TPO staff gave me the opportunity to share my story, all the while giving me their full attention. This made me feel much better than before when I kept it all in.





ខ្ញុំសូមឲ្យអ្នកដែលមានបទពិសោធន៍ស្រដៀងខ្ញុំ
មានឱកាសនិយាយពីរឿងរបស់ពួកគេ ដូចដែល
ខ្ញុំបានធ្វើ។ វាបានជួយឲ្យខ្ញុំធូរស្បើយ និងមាន
សុភមង្គលនៅក្នុងជីវិតរបស់ខ្ញុំម្តងទៀត។
ខ្ញុំសង្ឃឹមថា ប្រជាជនខ្មែរទាំងអស់នឹងរស់នៅ
ដោយភាពចម្រុងចម្រើនច្រើន ។

*I wish that those who have had similar experiences as me have the opportunity to tell their story like I did. It helped me feel relief and happiness in my life again. Hopefully, all Khmer people will live more prosperously.*



ខ្លូត ព្រិចា **Klot Pricha**

អតីតទាហានខ្មែរក្រហម *Former KR Soldier*

លើកទីមួយដែលខ្ញុំបានឃើញកងទ័ព
វៀតណាមលូនមកបោកគ្រាប់បែក
ខ្ញុំមានអារម្មណ៍រន្ធត់ និងភ័យខ្លាចជាខ្លាំង។
ខ្ញុំមិនធ្លាប់រៀនពី យុទ្ធសាស្ត្រសង្គ្រាមពីមុន
មកទេ។ លុះព្រឹកឡើង ខ្ញុំចេញល្បាត
កងទ័ពវៀតណាមបាញ់មកលើរូបខ្ញុំ។

*The first time I experienced a mortar attack by the Vietnamese army, I felt both shock and intense fear. I never received any training on the different tactics that were being used in the fighting. When I was on morning patrol one day, the Vietnamese army opened fire on me.*

ក្នុងឆ្នាំ១៩៧៥ គេបានតែងតាំងខ្ញុំជាប្រធានក្រុមកងចល័តកុមារ។ ក្នុងឆ្នាំ១៩៧៧ ខ្ញុំត្រូវបានបង្ខំឲ្យធ្វើជាទាហានខ្មែរក្រហម តែទោះជាយ៉ាងណាក៏ដោយខ្ញុំមិនចង់ប្រយុទ្ធគ្នានោះទេ ដូច្នេះខ្ញុំក៏សម្រេចចិត្តលួចទៅរស់នៅក្នុងព្រៃ។

ក្នុងឆ្នាំ១៩៨៣ ពុករបស់ខ្ញុំបានចូលរួមជាមួយទាហានខ្មែរក្រហម ហើយគាត់ក៏បានយកខ្ញុំទៅជាមួយគាត់ដែរ។ ទោះជាខ្ញុំមិនចង់ធ្វើទាហានក៏ដោយក៏ខ្ញុំនៅតែមិនអាចគេចផុតបានដែរ។ ទាហានវៀតណាមប្រើសុទ្ធតែអាវុធទំនើបៗ បាញ់មកលើពួកយើង នៅខណៈពេលនោះ ពួកខ្ញុំដែលនៅរស់មានជីវិត ក៏បានបែកគ្នាអស់។ ពួកខ្ញុំនៅសល់គ្នាត្រឹមតែ៧នាក់ ហើយត្រូវបង្ខំលាក់ខ្លួន។ ពេលនោះយើងយកដើមឈើ និងថ្មធ្វើជាជម្រក ហើយរាងកាយពោរពេញទៅដោយធូលី និងផេះ។ សត្វទាកខាំរមាស់ពេញខ្លួន។ យើងមិនដែលបានស្គាល់ទឹកងូតទេ ទឹកក៏គ្មានផឹក បាយក៏គ្មានហូប។ វាប្រៀបដូចយើងកំពុងនៅក្នុងពោះវៀនខ្មាំង។

បន្ទាប់ពីខ្ញុំចូលរួមការព្យាបាលរួច ការឈឺចាប់ និងការធ្លាក់ទឹកចិត្តរបស់ខ្ញុំបានធូរស្បើយ។ ការព្យាបាលបានជួយឲ្យខ្ញុំផ្សារភ្ជាប់ជាមួយនឹងការចងចាំដ៏ប្រេះស្រាំរបស់ខ្ញុំ ចងក្រងជាសាច់រឿងដើម្បីឲ្យយុវជនជំនាន់ក្រោយដឹង និងយល់ពីជីវិតអតីតទាហានខ្មែរក្រហម ខ្ញុំក៏បានរងទុក្ខវេទនាផងដែរក្នុងសង្គ្រាមជាង២០ឆ្នាំមកនេះ។



In 1975, I was appointed as a Child Mobile Unit leader. In 1977, I was forced to become a KR soldier, however, I didn't want to fight, so I deserted and went to live in the jungle.

In 1983, my father joined a group of KR soldiers and he took me with him. Being a soldier seemed unavoidable, even though I didn't want to be one. The Vietnamese troops had advanced weapons that wiped many of us out, while separating those that had survived. Only seven of us remained, which forced us into hiding. We used tree leaves and rocks as shelter and our bodies filled with dirt and ash as the time passed. Leeches began biting us, which caused my body to itch everywhere. We never got to bathe. We never had clean drinking water or rice to eat. It was as if we were living in the enemy's intestines.

After my participation in therapy, I was released from my pain and depression. The treatment helped me to integrate my fragmented memories into a coherent story for the next generation. I want them to know and understand that as a former Khmer Rouge soldier, I suffered as well during my 20 years of war.



ខ្ញុំសូមផ្តាំទៅប្រជាជនកម្ពុជា ឲ្យចេះថែរក្សាសន្តិភាព
ដោយការស្រឡាញ់ និងឲ្យតម្លៃទៅលើវា។

*I would like to give a message to the people of Cambodia:*
*Maintain peace by loving and cherishing it.*





# ញៀម ទួន Nhem Tuon

អតីតទាហានខ្មែរក្រហម *Former KR Soldier*

អ្វីដែលធ្វើឱ្យខ្ញុំពិបាក និងឈឺចាប់ខ្លាំងបំផុត គឺសំណួរមួយសួរមកថា "ម៉េចបានជាខ្ញុំទៅបម្រើរបបដែលជាអ្នកសម្លាប់អ្នកមានគុណរបស់ខ្លួនទៅវិញ?"

*What caused me to struggle the most was the question, "How could I serve the regime that was responsible for killing my parents?"*

ក្នុងឆ្នាំ១៩៧០ គេបានចាត់តាំងខ្ញុំឲ្យធ្វើជាឈ្លបឃុំបួនខែ។ ក្រោយមកទៀត ខ្ញុំធ្វើជាទាហាន។ ក្នុងឆ្នាំ១៩៧៦ ខ្ញុំត្រូវបានបញ្ជូនឲ្យទៅការពារព្រំដែនខ្មែរ ពីទាហានវៀតណាមដែលបុកមកកាន់តែខ្លាំងឡើងៗ។ ក្នុងឆ្នាំ១៩៨៥ កងទ័ពវៀតណាម បានវាយបុកមកដល់ស្រុកម៉ាឡៃ ហើយកាន់កាប់បានទាំងស្រុង។ ថ្នាក់ដឹកនាំខ្មែរក្រហមបានផ្ញើសារមួយទៅរដ្ឋាភិបាលប្រទេសថៃ ដើម្បីសុំកន្លែងសុវត្ថិភាពសម្រាប់ប្រជាជនកម្ពុជារស់នៅ។ ក្នុងពេលនោះថៃក៏បានរៀបចំជំរុំភៀសខ្លួន។ ខ្ញុំនិងគ្រួសារបានសម្រេចចិត្តរស់នៅក្នុងជំរុំនោះដែរ។ ពេលនោះខ្ញុំបានជួបជាមួយប្អូនប្រុសខ្ញុំ ហើយវាបាននិយាយប្រាប់ថា ឪពុកម្តាយរបស់យើងត្រូវបានគេសម្លាប់យ៉ាងអយុត្តិធម៌។ វាធ្វើខ្ញុំឈឺចាប់យ៉ាងខ្លាំងពេលឮដូចនេះ។

សង្គ្រាមបានបញ្ចប់ ហើយសោកនាដកម្មបានកន្លងផុតជាង៤០ឆ្នាំទៅហើយ។ ខ្ញុំធ្លាប់គិតថា ការរំលឹករឿងអតីតកាលរបស់ខ្ញុំឡើងវិញ គឺគ្មានប្រយោជន៍អ្វីសម្រាប់ខ្ញុំឡើយ។ ប៉ុន្តែការគិតរបស់ខ្ញុំ បានផ្លាស់ប្តូរក្នុងខែឧសភា ឆ្នាំ២០១៥ នៅពេលបុគ្គលិកអង្គការធីភីអូ បានមកជួបជាមួយនឹងខ្ញុំ។ ពីដំបូង ខ្ញុំស្ទាក់ស្ទើរក្នុងការនិយាយរឿងរ៉ាវទាំងនេះ។ ក៏ប៉ុន្តែបន្ទាប់ពីខ្ញុំបានចូលរួមព្យាបាលមក ខ្ញុំចាប់ផ្តើមដឹងថា វាមានប្រយោជន៍ណាស់ដែលខ្ញុំត្រូវនិយាយរឿងរ៉ាវពីអ្វីដែលខ្ញុំធ្លាប់ឆ្លងកាត់ និងការឈឺចាប់ដែលខ្ញុំបានជួប។ សំខាន់ជាងនេះទៅទៀតនៅពេលដែលខ្ញុំបានអានសាច់រឿងខ្ញុំឮៗ ខ្ញុំមានអារម្មណ៍ធូរស្រាលក្នុងចិត្ត។ ខ្ញុំយល់បានច្រើនពីអ្វីដែលបានកើតឡើងកន្លងមក។

ខ្ញុំសង្ឃឹមថាអ្នកផ្សេងទៀតដែលធ្លាប់ឆ្លងកាត់ហេតុការណ៍ឈឺចាប់ដូចខ្ញុំមានឱកាសនិយាយពីរឿងរ៉ាវរបស់ពួកគេ ដូចដែលខ្ញុំបាននិយាយរឿងរបស់ខ្ញុំចេញមកដែរ។





In 1970, I was appointed as a commune spy for four months and then I became a soldier. In 1976, I was sent to protect the Khmer border from the advancing Vietnamese army. In 1985, the Vietnamese army had advanced and completely controlled the Malai District. The KR leadership sent a request to the Thailand government which would allow some Cambodian people to live there safely. During that time, the Thais set up refugee shelters and my family and I decided to live in one. There, I met my younger brother and he told me our parents were killed unjustly. This caused me immense pain.

The wars have been over and the tragedies have been passed for more than 40 years now. I thought that recalling my past experiences would have no benefit for me. This changed in May of 2015, when a TPO staff member came to meet me. At first, I hesitated to talk about these things. However, after I participated in therapy, I started to realize that it was very important to disclose my story about what I went through and about the pain I have endured. More importantly, when I told my story aloud, I felt relieved. I had more clarity about what happened before. I wish that those who went through painful events like me could have the opportunity to give their testimony like I did.





យុវជនជំនាន់ក្រោយត្រូវរៀនពីរបបដ៏ឃោរឃៅ
មួយនេះ ព្រោះវាបានបន្សល់ទុកនូវរបួសផ្លូវចិត្ត
និងភាពឈឺចាប់វេទនាដល់ប្រជាជនជាច្រើន។

*The younger generation needs to learn about the brutality of this regime because it has left many people with psychological wounds and pain.*



## កង ជឹម Korng Chem

*អតីតទាហានខ្មែរក្រហម Former KR Soldier*

ពេលកំពុងនិយាយរឿងពីការវាយប្រយុទ្ធគ្នាក្នុងរបបនោះ ខ្ញុំហាក់បីដូចក្លិនរំសេវជាប់នៅនឹងខោអាវរបស់ខ្ញុំ។

*When talking about my past war experiences, I can still smell the gunpowder on my clothes.*

រឿងរ៉ាវរបស់ខ្ញុំប្រៀបដូចជារឿងមមាចដែលចូលចិត្តប្រលែងភ្លើងដែលវាមិនដឹងថាភ្លើងអាចនឹងធ្វើឲ្យវារលាកនិងឈឺចាប់នោះទេ។ ខ្ញុំបានប្រាប់កូនៗរបស់ខ្ញុំថា "បើដឹងថាសង្គ្រាមធ្វើឲ្យមហាសែនវេទនាលំបាកអញ្ចឹងនោះប្រហែលជាពុកមិនទៅធ្វើជាកងទ័ពសោះឡើយ"។

មុនពេលទទួលបានការព្យាបាល ខ្ញុំតែងមានការលំបាកដោយសារយល់សប្តិអាក្រក់ ការចងចាំទាំងនោះតែងមកលងខ្ញុំរាល់យប់។ បន្ទាប់ពីបានចូលរួមធ្វើសក្ខីកម្មមក ខ្ញុំមានអារម្មណ៍រីករាយកាន់តែខ្លាំង ដោយសារតែក្រុមគ្រួសារនិងសាច់ញាតិរបស់ខ្ញុំបានគាំទ្រ និងជឿចំពោះអ្វីដែលខ្ញុំបានជួបប្រទះ។ ខ្ញុំចាប់ផ្តើម គេងលក់ស្រួលជាងមុន លែងយល់សប្តិឃើញគេដេញបាញ់ក្នុងសង្គ្រាម និងមានកម្លាំងប្រសើរជាងមុន។

ខ្ញុំមានគំនិតផ្តាំដល់កូនដល់ចៅ ឬក្មេងៗជំនាន់ក្រោយថា៖ សូមឲ្យយើងទាំងអស់ត្រូវចេះស្រឡាញ់គ្នា កុំចង់ធ្វើសង្គ្រាមដាក់ខ្មែរគ្នាឯងទៀត ពីព្រោះវាធ្វើឲ្យមនុស្សត្រូវស្លាប់ព្រាត់ប្រាស់គ្នា ខ្លះក៏ត្រូវភៀសខ្លួនរត់ចោលផ្ទះសំបែងបាត់បង់ទ្រព្យសម្បត្តិ ស្អប់គ្នាប្រកាន់បក្សពួក ខ្មែរមើលមុខគ្នាលែងចំ ប្រទេសជាតិលិចលង់អស់ ប្រទេសជិតខាងគេមើលងាយ។

ខ្ញុំសំណូមពរដល់អង្គការធីភីអូ ឲ្យបង្កើនធ្វើសកម្មភាពនេះដល់ជនរស់រានមានជីវិតផ្សេងៗទៀត។ ខ្ញុំជឿជាក់ថា ការព្យាបាលនេះអាចនឹងជួយអ្នកផ្សេងទៀតដូចដែលវាបានជួយខ្ញុំដូច្នេះដែរ។



My story is similar to the one about the cattle pests that liked flying close to fire, but didn't know that the fire could hurt or burn them. I told my children that if I had known that the war would have caused me so much suffering, I never would have become a soldier.

Before treatment, I usually suffered from nightmares; my memories always came to haunt me at night. After receiving therapy, I felt happier because my family and relatives gave me more support, but most importantly, they believed me. Additionally, I have been sleeping better with fewer nightmares and now have more energy.

I would like to give this message to all future generations: Please love each other. Don't allow Khmers to fight each other. This only leads to death, separation, poverty, displacement, discrimination, hatred, and in the end—the destruction of our entire country. I would also like to suggest that TPO provide this treatment to other survivors. I believe it would serve them as it did me.



ខ្ញុំតែងតែប្រាប់កូនៗរបស់ខ្ញុំថា យើងត្រូវចេះស្រលាញ់គ្នា
មិនមិនត្រូវធ្វើសង្គ្រាមប្រឆាំងនឹងខ្មែរគ្នាឯងឡើយ។
ឪធ្អែតហើយចំពោះការធ្វើសង្គ្រាម ពីព្រោះវាបានធ្វើឲ្យ
មនុស្សព្រាត់ប្រាស់គ្នា និងសម្លាប់ជីវិតមនុស្ស។

*I always tell my children that we should all love each other and not wage war against other Khmer people. I was so fed up with the war because it separated and killed people.*



| | |
|---|---|
| អ្នកសម្របសម្រួលគម្រោង | កញ្ញា អោម ចរិយា |
| អ្នកអភិបាលកិច្ច | លោក ពេជ បញ្ញា |
| អ្នកប្រឹក្សាបច្ចេកទេសគ្លីនីក | លោកបណ្ឌិត Edward Palmer |
| អ្នកកែសម្រួលភាសាខ្មែរ | អ្នកស្រី ជ សុណារី កញ្ញា អោម ចរិយា កញ្ញា សោម វត្ថនា<br>កញ្ញា ហៀក សុឃឿន លោក ស៊ាង លាប |
| អ្នកកែសម្រួលជាភាសាអង់គ្លេស | កញ្ញា Rhiana Holmes លោកបណ្ឌិត Edward Palmer |
| អ្នកប្រឹក្សាផ្លូវចិត្តរបស់គម្រោង ការស្វែងរកពិត<br>ការផ្សះផ្សា និងភាពជាសះស្បើយ | កញ្ញា អោម ចរិយា លោក គឹម សោភ័ណ អ្នកស្រី ជ សុណារី<br>លោក យូ អ៊ិល សុជាតិ កញ្ញា សោម វត្ថនា កញ្ញា ថ្លែន សុគន្ធណារ៉ា |
| ថតរូបដោយ | លោក ញ៉ែម ពិសិដ្ឋ |
| រចនាក្រាហ្វិកដោយ | សារ៉ាវ៉ាន់ (Saravan.co) |

| | |
|---|---|
| **Project Coordinator** | Om Chariya, M.A. |
| **Clinical Supervisor** | Pich Panha, M.P.H. |
| **Clinical Advisor** | Edward Palmer, Ph.D. |
| **Khmer Editors** | Chor Sonary, Om Chariya, M.A., Sorm Rathana, Hiek Sokhoeun, Seang Leap, M.P.A. |
| **English Editors** | Rhiana Holmes, Edward Palmer, Ph.D. |
| **TPO Counselors for the Truth, Reconciliation, and Healing Project** | Om Chariya, Kim Sophornn, Chor Sonary, You Il Sochet, Sorm Rathana, Thlen Sokunnara |
| **Photos by** | Nhem Piseth |
| **Graphic Design by** | Saravan.co |

*អ្វីដែលធ្វើឲ្យខ្ញុំឈឺចាប់បំផុតអស់រយៈពេលជាង*
*៣០ឆ្នាំគឺការព្យាយាមរកចម្លើយ “តើខ្ញុំជាអ្នកណា?”*

*What caused me the most pain for 30 years was my*
*attempt to answer the question, “Who am I?”*